# ឌុច គ្រូបានគេចាត់ទុកថា ជាសិស្សដែលមិនគិតពីខ្លួនឯង និងជាគ្រូដែលមានការលះបង់

*ដោយ ម៉ៃ ទឹល សាលីបា*

*ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ឌី សុជាតា*

*សាលាជំនុំជម្រះក្តីបានឮពីសក្ខីកម្មសាក្សីបួនរូប ដែលស្គាល់ជនសង្ស័យ កាំង ហ្គេកអ៊ាវ ហៅ ឌុច ពេលនៅជាសិស្សនិងជាគ្រូបង្រៀនម្នាក់ ។ ប៉ុន្តែមុនពេលដែលសាក្សីទាំងនេះបានធ្វើសក្ខីកម្ម មេធាវីការពារក្តីបានបញ្ចប់សំនួររបស់សាក្សីជំនាញ ហ្វ្រង់ស្វ័រ ស៊ីរ៉ូនី ហ្គីបូដ និង កា ស៊ុនបូណាត ។ តាមរយៈការសួររបស់គាត់ សហមេធាវីអន្តរជាតិ ហ្វ្រង់ស្វ័រ រូហ្ស បានព្យាយាមចង្អុលបង្ហាញពីភាពស្មោះត្រង់ចំពោះវិប្បដិសារីរបស់ ឌុច ដែលធ្លាប់បានជជែកគ្នាយ៉ាងខ្លាំងនៅក្នុងនីតិវិធីទាំងមូល ។ គាត់បានរៀបរាប់ប្រាប់អ្នកជំនាញពីសកម្មភាព និងសេចក្តីថ្លែងការណ៍របស់ ឌុច ដូចជាការសុំទោសយ៉ាងរំជួលចិត្ត ការស្ម័គ្រចិត្តចូលរួមក្នុងការអនុវត្តឡើងវិញ នៅគុកទួលស្លែង (មន្ទីរស-២១) និងវាលពិឃាតបឹងជើងឯក ។*

*លោក រូហ្ស បានពិនិត្យម្តងទៀតលើរឿង ឌុច អាចចូលចុះក្នុងសង្គមដែលត្រូវបានជំទាស់ដោយស្ថាប័នអយ្យការកាលពីម្សិលមិញ ។ លោក រូហ្ស បានរំលឹកសេចក្តីថ្លែងការរបស់សាក្សីជំនាញឡើងវិញថា មនុស្សម្នាក់កើតមកមិនមែនមានចិត្តចង់សម្លាប់គេទេ ប៉ុន្តែអ្នកនោះក្លាយទៅជាអ្នកសម្លាប់គេទៅវិញ ។ ការប្រព្រឹត្តកុវិជ្ជាដូចគ្នានេះដែរ អ្នកជំនាញជាច្រើនយល់ស្របថា មនុស្សម្នាក់ដូចជា ឌុច អាចមាន«ភាពជាមនុស្ស»ម្តងទៀត ។ ម្យ៉ាងទៀត គាត់អាចមាននីតិសម្បទា និងអាចចូលចុះក្នុងសង្គមវិញ ។*

## *សាក្សីរៀបរាប់ពីបុគ្គលិកលក្ខណៈរបស់ ឌុច ក្នុងនាមជាសិស្ស និងជាគ្រូម្នាក់*

*ឌុច អតីតសិស្សរួមថ្នាក់វិទ្យាល័យជាមួយ ស៊ូ សាត ហើយគាត់រៀបរាប់អំពី ឌុច ថាជាសិស្សដែលមានចិត្តល្អ និងសប្បុរស ។ ខណៈពេលដែលសិស្សជាច្រើនមានការស្ទាក់ស្ទើរក្នុងការជួយសិស្សដ៏ទៃទៀត ឌុច តែងតែមានឆន្ទៈក្នុងការជួយសិស្សរួមថ្នាក់ និងចែករំលែកចំណេះដឹងរបស់គាត់ ។ លើសពីនេះទៅទៀត ស៊ូ សាត មិនធ្លាប់បានឃើញ ឌុច មានការទាស់សំដី ទំនាស់ផ្លូវកាយ ឬទំនាស់*

ប្រាជ្ញាជាមួយសិស្ស ឬគ្រូណាម្នាក់នោះទេ ។ (អង្គជំនុំជម្រះអនុញ្ញាតអោយ ស៊ូ សាត សួរសុខទុក្ខ ឌុច បន្ទាប់ពីធ្វើសក្ខីកម្ម ដូចជាការអនុវត្តទូទៅនៅក្នុងនីតិវិធីព្រហ្មទណ្ឌអន្តរជាតិជាច្រើនដែរ) ។ ទេព សែម និង ទេព សុខ រៀបរាប់ថា ទាក់ទងនឹងប៉ុន្មានឆ្នាំដែល ឌុច គឺជាគ្រូម្នាក់ ដែលមានការលះបង់ និងជាអតីតសិស្សវិទ្យាល័យ ។ ទេព សែម ថា ឌុច ជាគ្រូសុភាពរាបសា និងមានស្មារតីខ្ពស់ម្នាក់ដែលមិនខ្វល់ពីវណ្ណៈសិស្សនោះទេ ។ ទេព សែម បានពន្យល់ថា ឌុច បានផ្តល់នូវការបង្រៀនជាឯកជនដោយមិនគិតថ្លៃពីសិស្សដែលត្រូវការជំនួយបន្ថែម ។ ទេព សែម បន្ថែមទៀតថា ឌុច ជាគ្រូម្នាក់ដែលមានចិត្តល្អ និងសុភាពរាបសារ ហើយ ឌុច បានបរិច្ចាគសៀវភៅដល់សិស្សនិងតែងតែជួយដល់សិស្សដែលត្រូវការជំនួយខាងក្រៅបន្ថែមទៀត ។ ជូ វិន ដែលជាអ្នកបង្រៀននៅអែបនឹង ឌុច នៅឯសាលាមួយនៅក្នុងភូមិផ្គាំ ចាប់ពីឆ្នាំ១៩៩៥រហូតដល់១៩៩៧ បានពន្យល់ផងដែរថា ឌុច ត្រូវបានគេចូលចិត្ត និងទទួលការគោរពពីសិស្ស ដែលពេលខ្លះគាត់ត្រូវបានគេហៅថា «លោកគ្រូតា» ។

សាក្សីទាំងនេះ បានសម្តែងពីភាពតក់ស្លុតទៅលើការដឹងពីតួនាទីរបស់ ឌុច នៅមន្ទីរស-២១ ។ ទេព សុខ បានរៀបរាប់ពីអារម្មណ៍សោកស្តាយនៅពេលដែលបានឮពត៌មាន ព្រោះគាត់ធ្លាប់គិតថា ឌុច ជាមនុស្សមានគុណធម៌ម្នាក់បែរជាមកទទួលទោសព្រហ្មទណ្ឌ ។ ស៊ូ សាត «ស្រឡាំងកាំង និងស្ងន់ស្ងោ» នៅពេលនាងដឹងថា ម្នាក់ក្នុងចំណោមគ្រូរបស់ ឌុច ត្រូវបានឃុំខ្លួន និងធ្វើទារុណកម្មនៅមន្ទីរស-២១ ។

## មេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ព្យាយាមបញ្ជាក់ពីភាពទោមនស្សរបស់កូនក្តីចំពោះអង្គជំនុំជម្រះ

សព្វថ្ងៃនេះមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន បន្តនូវសម្លេងទោមនស្សរបស់កូនក្តីជាមួយ និងសេចក្តីសម្រេចតុលាការ ដែលជាឧបសគ្គក្នុងការសាកសួរដើមបណ្តឹងរដ្ឋប្បវេណីក្នុងនាមជាសាក្សី ។ នៅពេលចាប់ផ្តើមនៃការប្រជុំ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោក អាឡាំង វែនណឺរ (Alain Werner) បានស្នើទៅអង្គជំនុំជម្រះសាលាដំបូងសម្រាប់ការអនុញ្ញាតអានលិខិតចំហរពីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីកត់ត្រាទុក ។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើលោក វែនណឺ និងបដិសេធនូវការស្នើសុំដាក់លិខិតជាថ្មីមកតុលាការ ។

នៅពេលចុងបញ្ចប់នៃថ្ងៃដដែលនោះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានស្នើទៅកាន់អង្គជំនុំជម្រះដើម្បីពន្យល់ទៅសាក្សីពីមូលហេតុ នៃអវត្តមានដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា វាមានសារៈសំខាន់ណាស់សម្រាប់សាក្សីក្នុងការដឹងពីមូលហេតុចំពោះអ្វីដែលពួកគេមិនបានសួរពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ ទោះយ៉ាងណាក៏ដោយហាក់បីដូចជា

ប្រាប់នូវហេតុផលដំបូង ដោយចេតនាបង្កឲ្យតុលាការដឹងពីភាពមិនពេញចិត្តរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដូច្នេះអាចព្យាករណ៍បានថាសាលាក្តីច្រានចោលសំណើទីមួយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ទីពីរ សាលាក្តីបានបញ្ជាក់ពីភាពរសាយចិត្តរបស់ខ្លួនដោយសំណើដដែលៗទាំងនេះ ។ ចុងក្រោយ បន្ទាប់ពីសំណើទីបី សាលាក្តីបានបញ្ឈប់សិទ្ធប្រើឧបករណ៍បំពងសម្លេងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងហាមឃាត់មិនឲ្យជ្រៀតចូលខណៈពេលដែលនៅមានសាក្សីផ្តល់ភស្តុតាងពីអត្តចរិត ។ ព្រឹត្តការណ៍បន្ថែមក្នុងថ្ងៃនេះបានធ្វើឲ្យទំនាក់ទំនងរវាងតុលាការ និងដើមបណ្តឹងរដ្ឋប្បវេណីកាន់តែមានភាពតានតឹងឡើង ។ ដើមបណ្តឹងរដ្ឋប្បវេណីមានអារម្មណ៍ថា សិទ្ធរបស់គាត់ត្រូវបានកម្រិតហួសហេតុហើយពេលនេះពួកគាត់គិតថា តុលាការនេះ គឺស្ទាក់ស្ទើរក្នុងការស្តាប់នូវអ្វីដែលពួកគាត់ដឹងថា ជាការតវ៉ាតាមផ្លូវច្បាប់ ។

មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ និងក្រុម ៤ អវត្តមាននៅថ្ងៃទីពីរ ។ គ្មានការចង្អុលបង្ហាញណាមួយដែលត្រូវបានផ្តល់ឲ្យដើម្បីពន្យល់ពីអវត្តមានរបស់ពួកគេ ហើយវាគឺជាភាពមិនច្បាស់លាស់ប្រសិនបើវាជាប់ទាក់ទងទៅនឹងការធ្វើពហិការ ។ ការវិវត្តរហូតមកដល់ថ្ងៃនេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៅតែមិនទាន់ត្រូវបានជ្រើសរើសឲ្យចូលរួមក្នុងដំណើរការនីតិវិធី រហូតដល់សេចក្តីសន្និដ្ឋាននៃសក្ខីកម្មសាក្សីដែលផ្តល់ភស្តុតាងអំពីអត្តចរិត ។